# អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

## Kampuchea Action to Promote Education (KAPE)

## សេចក្តីជូនដំណឹងស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃជួសជុលបន្ទប់សិក្សាសម្រាប់បណ្ណាល័យ/បន្ទប់កុំព្យូទ័រ និងបំពាក់គ្រឿងសង្ហារឹម នៅក្នុងសាលារៀនគោលដៅរបស់គម្រោង "លើកកម្ពស់ការអប់រំឌីជីថលសម្រាប់សិស្សានុសិស្ស" ក្រោមជំនួយថវិកាដោយ អង្គការ មូលនិធិកុមារកូរ៉េ (ប្រទេសកូរ៉េ ខាងត្បូង)

អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) សូមជម្រាបជូនដំណឹងដល់ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ក្នុងស្រុកទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា៖ គម្រោង "លើកកម្ពស់ការអប់រំឌីជីថលសម្រាប់សិស្សានុសិស្ស" នៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ **ទទួលការងារជួសជុលបន្ទប់សិក្សាសម្រាប់បណ្ណាល័យ/បន្ទប់កុំព្យូទ័រ និងបំពាក់គ្រឿងសង្ហារឹមនៅក្នុងសាលារៀនគោលដៅចំនួន ១១សាលា នៅក្នុងខេត្ត កណ្តាល និងរាជធានី ភ្នំពេញ** (មានបញ្ជីឈ្មោះសាលារៀនជូនភ្ជាប់)។

ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ទាំងអស់ដែលមានប្រភេទតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថា៖ ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ដែលបានចូលរួមធ្វើការដេញថ្លៃ ជាក្រុមហ៊ុន និងអ្នកម៉ៅការសំណង់មានសម្ព័ន្ធភាពជាមួយ ឬប្រភេទតែមួយ នឹងត្រូវបដិសេធដោយស្វ័យប្រវត្តិ។

ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ ដែលមានចំណាប់អារម្មណ៍សូមធ្វើការទាក់ទងមកអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ដើម្បីសាកសួរព័ត៌មានអំពីការចូលរួមដេញថ្លៃ និងការរៀបចំឯកសារភ្ជាប់ក្នុងការបញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ ចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤ ម៉ោង៥:០០នាទីល្ងាចជាកំហិត តាមរយៈសារអេឡិចត្រូនិច (អ៊ីមែលជូនភ្ជាប់) ព្រមទាំងចម្លងជូន (CC) មកអ្នកពាក់ព័ន្ធទាំងអស់។

អង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) នឹងធ្វើការប្រជុំតម្រង់ទិសអំពីនិតិវិធីនៃការបំពេញសម្រង់តម្លៃសម្រាប់ចូលរួមដេញថ្លៃដោយផ្ទាល់ដែលប្រព្រឹត្តិទៅនៅ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២៤ វេលាម៉ោង ០៩:០០នាទីព្រឹក ដែលមានអាសយដ្ឋាននៅការិយាល័យរង សាលារៀនជំនាន់ថ្មី (ស្ថិតនៅក្នុងបរិវេណវិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានី ភ្នំពេញ)។

ក្រោយពីការប្រជុំតម្រង់ទិសរួច អង្គការ/គម្រោង តម្រូវឱ្យក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ទាំងអស់ចុះទៅសិក្សាស្វែងយល់នៅតាមសាលារៀនគោលដៅទាំង ១១សាលា ដើម្បីរៀបចំឯកសារដេញថ្លៃ (មានឯកសារជូនភ្ជាប់)។ ប្រសិនបើមានក្រុមហ៊ុន និងអ្នកម៉ៅការណាមួយ ដែលមិនបានចុះសិក្សាស្វែងយល់ដល់សាលារៀនគោលដៅទាំង ១២សាលាទេ អង្គការ/គម្រោង មិនផ្តល់សិទ្ធិឱ្យចូលរួមដេញថ្លៃឡើយ។

ក្រោយពីចុះសិក្សា ស្វែងយល់ដល់សាលារៀនគោលដៅរួចមក ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ទាំងអស់ ត្រូវរៀបចំឯកសារសម្រាប់ចូលរួមដេញថ្លៃ និងតម្រូវឱ្យដាក់តំកល់ប្រាក់កក់ចំនួន ៥% នៃតម្លៃដេញថ្លៃសរុប (ក្នុងមួយផ្នែក) ដើម្បីមានសិទ្ធិចូលរួមដេញថ្លៃការងារជួសជុលបន្ទប់សិក្សាសម្រាប់បណ្ណាល័យ/បន្ទប់កុំព្យូទ័រ និងបំពាក់គ្រឿងសង្ហារឹម ព្រមទាំងប្រគល់កញ្ចប់ដេញថ្លៃជូនមកការិយាល័យរដ្ឋបាលនៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា យ៉ាងយូរបំផុតត្រឹម ថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០២៤ វេលាម៉ោង ០៤:០០នាទីល្ងាចជាកំហិត។

ចំពោះការបើកកញ្ចប់ឯកសារដេញថ្លៃនឹងប្រព្រឹត្តិទៅដោយផ្ទាល់នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៤ ដែលមានអាសយដ្ឋាននៅការិយាល័យរង សាលារៀនជំនាន់ថ្មី (ស្ថិតនៅក្នុងបរិវេណវិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានី ភ្នំពេញ)។

<u>បញ្ជាក់៖</u>

- ការទទួលឯកសារភ្ជាប់បញ្ជាក់លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ ចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង ៥:០០នាទីល្ងាចជាកំហិត តាមរយៈសារអេឡិចត្រូនិច (អ៊ីមែលជូនភ្ជាប់) ព្រមទាំងចម្លងជូន (CC) មកអ្នកពាក់ព័ន្ធទាំងអស់។

- ប្រជុំតម្រង់ទិសអំពីនិតិវិធីនៃការបំពេញសម្រង់តម្លៃសម្រាប់ចូលរួមដេញថ្លៃដោយផ្ទាល់នឹងប្រព្រឹត្តិទៅ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២៤ វេលាម៉ោង ០៩:០០នាទីព្រឹក ដែលមានអាសយដ្ឋាននៅការិយាល័យរង សាលារៀនជំនាន់ថ្មី (ស្ថិតនៅក្នុងបរិវេណវិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានី ភ្នំពេញ) យើងមិនទទួលខុសត្រូវក្នុងការបើកកញ្ចប់ដេញថ្លៃទេ ប្រសិនគ្រប់ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ មិនអញ្ជើញមកចូលរួមស្តាប់ការណែនាំ និងការតម្រង់ទិសក្នុងការជំនួយស្មារតីនៃការចូលរួមដេញថ្លៃ មានដូចជា៖ (ប្លង់ រូបភាព ទីតាំងសាលារៀន និងផ្សេងទៀត)។
- រាល់ឯកសារសម្រង់តម្លៃ (ត្រូវបញ្ចូលពន្ធអាករលើតម្លៃបន្ថែម ១០%) និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ត្រូវច្រកក្នុងស្រោមបិទជិត ដោយមានចុះហត្ថលេខា និងបោះត្រារបស់ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ នៅលើស្រោមសំបុត្រ រួចបញ្ជូនមកការិយាល័យរដ្ឋបាល នៃអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) ចាប់ពីថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២៤ ដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ វេលាម៉ោង ០៤:០០នាទីល្ងាចជាកំហិត ដែលមានអាសយដ្ឋាននៅការិយាល័យរង សាលារៀនជំនាន់ថ្មី (ស្ថិតនៅក្នុងបរិវេណវិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានី ភ្នំពេញ) ហើយមិនអនុញ្ញាតឱ្យដាក់មកតាមរយៈសារអេឡិចត្រូនិច (អ៊ីមែល) បានជាដាច់ខាត។
- គ្រប់ក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ទាំងអស់ អាចចូលរួមដេញថ្លៃបាន លុះត្រាតែក្រុមហ៊ុន និងអ្នកម៉ៅការសំណង់នោះបានចុះមើលទីតាំងសាលារៀនគោលដៅដោយផ្ទាល់ ដើម្បីងាយស្រួលធ្វើការប្រៀបធៀបជាមួយ BoQ ដែលបានផ្តល់ដោយគម្រោង ហើយមានការបោះត្រាទទួលស្គាល់ពីនាយក/នាយករង សាលារៀនគោលដៅថាពិតជាបានចុះពិនិត្យមើលត្រឹមត្រូវពិតប្រាកដមែន។
- រាល់ឯកសារសម្រង់តម្លៃ និងពាក្យសុំចូលរួមការដេញថ្លៃទាំងអស់ ដែលមិនបានដាក់ជូនមកការិយាល័យរដ្ឋបាលរបស់អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ទាន់ពេលវេលាទេ ត្រូវចាត់ទុកជាអាសាបង់។
- អ្នកចូលរួមដេញថ្លៃទាំងអស់ ត្រូវអញ្ជើញមកចូលរួមប្រជុំស្តាប់ការបើកកញ្ចប់ដេញថ្លៃឱ្យទាន់ពេលវេលា។ ប្រសិនបើអ្នកដេញថ្លៃណាដែលមិនបានចូលរួមប្រជុំបើកកញ្ចប់ដេញថ្លៃទាន់ពេលវេលា ឬក៏អវត្តមានក្នុង(រយៈពេល១៥នាទី)ឯកសារដាក់ដេញថ្លៃនោះមិនអនុញ្ញាតដាក់បញ្ចូលក្នុងការបើកឡើយ។
- ចំពោះអ្នកចូលរួមប្រជុំការបើកកញ្ចប់ឯកសារដេញថ្លៃទាំងអស់ដែលជាអ្នកមកតំណាងក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ត្រូវមានលិខិតផ្ទេរសិទ្ធិ ដែលមានចុះហត្ថលេខាត្រឹមត្រូវពីប្រធានក្រុមហ៊ុន និងម្ចាស់អ្នកម៉ៅការសំណង់។
- យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរកាលបរិច្ឆេទនៃការបើកកញ្ចប់ដេញថ្លៃ ប្រសិនបើមានការចាំបាច់ ហើយយើងខ្ញុំនឹងជូនដំណឹងជាមុនទៅក្រុមហ៊ុន និងអ្នកម៉ៅការសំណង់ ដែលបានផ្ញើឯកសារដេញថ្លៃមក។
- រាល់ឯកសារដែលដាក់មកហើយ គណៈកម្មការយើងខ្ញុំមិនប្រគល់ជូនត្រឡប់ទៅវិញទេ។

**ព័ត៌មានផ្សេងៗសូមទំនាក់ទំនង៖**


ការិយាល័យកណ្តាលអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប )

អាសយដ្ឋាន ៖ ក្នុងបរិវេណសាលាគរុកោសល្យ និងវិក្រឹតការ ខេត្ត កំពង់ចាម

ឈ្មោះ ៖ លោក ឈួន សារ៉ាន ជាប្រធានរដ្ឋបាល និងធនធានមនុស្ស

៖ លោក ផា ស៊ីណាក់ ជាវិស្វករសំណង់ គម្រោង សាលារៀនជំនាន់ថ្មី

៖ លោក ស សុផាណាក់ ជាប្រធានគម្រោង លើកកម្ពស់ការអប់រំឌីជីថលសម្រាប់សិស្សានុសិស្ស

ទូរសព្ទ ៖ ០១២ ៧៥២ ៥៥៣, ០៩៦ ៤៦៤ ៧៧៧៧

អ៊ីមែល ៖ saran@kapekh.org,

ចម្លងជូន ៖ vanna@kapekh.org, sambath@kapekh.org, sophanak@kapekh.org, veasna@kapekh.org, vannak_eng@kapekh.org, sinak.pha@kapekh.org


ថ្ងៃព្រហស្បតិ៍ ២រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

កំពង់ចាម, ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤

**នាយកប្រតិបត្តិ**

**សៅ-វណ្ណា**